00817786

E202/3.1



**ឧបសម្ព័ន្ធ ក**

**សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក**

[កាលបរិច្ឆេទ]

**ជូនចំពោះ៖** [ឈ្មោះសាក្សី, អាសយដ្ឋាន, និងថ្ងៃខែឆ្នាំកំណើត]

# លិខិតធានាអំពីការមិនចោទប្រកាន់

លោក/លោកស្រី ត្រូវបានកោះហៅឱ្យចូលបង្ហាញខ្លួនក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ គោលបំណងនៃផ្តល់សក្ខីកម្មរបស់ លោក/លោកស្រី គឺដើម្បីជួយដល់ចៅក្រមនៃ អ.វ.ត.ក ស្វែងរកការពិត អំពីហេតុការណ៍ដែលបានកើតឡើងនៅកម្ពុជា ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

នាពេលបច្ចុប្បន្ន អ.វ.ត.ក គឺជាតុលាការតែមួយគត់នៅកម្ពុជាដែលបាន ~~អាច~~ចោទប្រកាន់បុគ្គលដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសក្នុងអំឡុងរយៈកាលខាងលើ។ បុគ្គលទាំងនេះត្រូវតែជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តកាលពីក្នុងអំឡុងរយៈកាលនោះ។

លិខិតនេះមានគោលបំណងជូនដំណឹងដល់លោក/លោកស្រីថា៖

~~១. យើង~~សហព្រះរាជអាជ្ញានៃ អ.វ.ត.ក នឹងមិនផ្តួចផ្តើមការចោទប្រកាន់ណាមួយទៅលើលោក/លោកស្រី ចំពោះហេតុការណ៍ណាមួយ ដែលបានកើតឡើងនៅកម្ពុជាក្នុងអំឡុងរយៈកាលចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នោះទេ។

~~២. អនុលោមតាមច្បាប់កម្ពុជាបច្ចុប្បន្ន លោក/លោកស្រី មិនអាចត្រូវបានចោទប្រកាន់ដោយតុលាការជាតិកម្ពុជាណាមួយឡើយ ចំពោះព្រឹត្តិការណ៍ណាមួយដែលបានកើតឡើងក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។~~

ក្នុងឋានៈជាសាក្សី លោក/លោកស្រី មានកាតព្វកិច្ចចំពោះមុខច្បាប់ក្នុងការប្រាប់តែការពិតមួយមុខគត់ដល់តុលាការ។ គោលបំណងនៃការផ្តល់ជូននូវលិខិតធានានេះគឺដើម្បីទុកលទ្ធភាពឲ្យលោក/លោកស្រី និយាយឲ្យបានទូលំទូលាយ និងដោយស្មោះត្រង់នៅចំពោះមុខតុលាការ ~~ដោយគ្មានការភ័យខ្លាចពីការចោទប្រកាន់ណាមួយឡើយ~~ ដោយផ្អែកលើ ព័ត៌មានត្រឹមត្រូវពាក់ព័ន្ធនឹងផលវិបាកនៃសក្ខីកម្មរបស់លោក/លោកស្រីនៅចំពោះមុខ អ.វ.ត.ក ។

ច្បាប់ចម្លងនៃលិខិតធានានេះនឹងត្រូវចូលទៅក្នុងសំណុំរឿង ដើម្បីធ្វើជាកំណត់ហេតុបញ្ជាក់ថា លោក/លោកស្រី បានទទួលនូវការធានានេះ។

| | |
|---|---|
| ______________________ | ______________________ |
| **ជា លាង** | Andrew Cayley |
| **សហព្រះរាជអាជ្ញាជាតិ** | **សហព្រះរាជអាជ្ញាអន្តរជាតិ** |
| កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ |

ខ្ញុំសូមបញ្ជាក់ថាខ្ញុំបានទទួល និងយល់អំពីការធានានេះ។

ហត្ថលេខា៖

______________________

[ឈ្មោះសាក្សី]